**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

លេខ ៣៥១ ព.ម ប្រក

ថ្ងៃអង្គារ ៨រោច ខែភទ្របទ ឆ្នាំច សំរិទ្ធស័ក ពស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៨

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មផ្នែរមុខងារការផ្តល់សេវារដ្ឋបាល លើវិស័យព័ត៌មាន ជូនរដ្ឋបាលរាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ខែកញ្ញាឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ចុះថ្ងៃទី២៨ខែមិថុនាឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ខែឧសភាឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ៧០អនក្រ.បក ចុះថ្ងៃទី០៥ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងព័ត៌មាន

-បានឃើញអនុក្រឹត្យលេខ៧១អនក្រ.បក ចុះថ្ងៃទី១៣ខែកក្កដាឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល-សោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍នៃក្រសួងព័ត៌មាន

-បានឃើញអនុក្រឹត្យលេខ១៨អនក្រ.បកចុះថ្ងៃទី០៨ខែកុម្ភៈឆ្នាំ២០១៧ស្តីពីការបង្កើតច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១០ខែឧសភាឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញអនុក្រឹត្យលេខ២៦អនក្រ.បកចុះថ្ងៃទី២១ខែកុម្ភៈឆ្នាំ២០១៣ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញបទបញ្ជាលេខ០៤បប ចុះថ្ងៃទី១៥ខែវិច្ឆិកាឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

-បានឃើញប្រកាសរួមលេខ១០០៣សហវ.ប្រក ចុះថ្ងៃទី២៨ខែធ្នូឆ្នាំ២០១២ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព័ត៌មាន

-បានឃើញប្រកាសរួមលេខ១០០៤សហវ.ប្រក ចុះថ្ងៃទី២៨ខែធ្នូឆ្នាំ២០១២ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងព័ត៌មាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញប្រកាសលេខ៣៨៧១ប្រក ចុះថ្ងៃទី០៨ខែសីហាឆ្នាំ២០១៧ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-បានឃើញប្រកាសលេខ៣៨៥៦ប្រក ចុះថ្ងៃទី០២ខែធ្នូឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-យោងតម្រូវការចាំបាច់របស់ក្រសួងព័ត៌មាន។

អាសយដ្ឋាន: អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

## សម្រេច

**ប្រការ១**: ត្រូវបានធ្វើប្រតិភូកម្មផ្ទេរមុខងារការផ្តល់សេវារដ្ឋបាលលើវិស័យព័ត៌មានដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសនេះ ជូនរដ្ឋបាលរាជធានី ខេត្ត នៅក្នុងក្របខណ្ឌដែនដី និងសមត្ថកិច្ចរបស់ខ្លួន បន្ថែមលើមុខងារការផ្តល់សេវារដ្ឋបាលលើវិស័យព័ត៌មាន ដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ២** :មន្ទីរព័ត៌មានរាជធានី ខេត្ត មានតួនាទីជាសេនាធិការឲ្យរដ្ឋបាលរាជធានី ខេត្ត ក្នុងការអនុវត្តមុខងារដែលត្រូវបានធ្វើប្រតិភូកម្មនេះ ដោយត្រូវចាត់តាំងអនុប្រធានមន្ទីរ ០១រូប ដែលមានសមត្ថភាពឲ្យទៅបំពេញការងារនៅអង្គភាពច្រកចេញចូលតែមួយតាមច្បាប់កំណត់ ដើម្បីគាំទ្រផ្នែកបច្ចេកទេសដល់ការបំពេញការងារផ្តល់សេវារដ្ឋបាលលើវិស័យព័ត៌មាននៅរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ៣**: រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់សេវារដ្ឋបាលលើវិស័យព័ត៌មាន ជូនប្រជាពលរដ្ឋដូចមានចែងនៅក្នុងប្រការ១ នៃប្រកាសនេះ ឲ្យមានគុណភាព ប្រសិទ្ធភាព និងមានតម្លាភាព។ យន្តការ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលលើវិស័យព័ត៌មាននៅរដ្ឋបាលរាជធានី ខេត្តត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន និងប្រកាសលេខ៣៨៧១ ប្រក ចុះថ្ងៃទី០៨ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ៤**: រដ្ឋបាលរាជធានី ខេត្ត ត្រូវបិទផ្សាយជាសាធារណៈលើក្តារព័ត៌មាននៅកន្លែងផ្តល់សេវារដ្ឋបាលច្រកចេញចូលតែមួយ និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលលើវិស័យព័ត៌មានព្រមទាំងធ្វើការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលនេះ តាមគ្រប់មធ្យោបាយផ្សេងៗ អំពីកម្រងសេវារដ្ឋបាល ទម្រង់បែបបទ នីតិវិធី លក្ខខណ្ឌសម្រាប់ការផ្តល់សេវា ការបង់ថ្លៃសេវារដ្ឋបាល និងការបង់ថ្លៃសេវាសោតទស្សន៍ជាដើម។

**ប្រការ៥** : រាល់ការផ្តល់សេវារដ្ឋបាលលើវិស័យព័ត៌មាន នៅរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមកម្រងសេវារដ្ឋបាលដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលនៃការផ្តល់សេវា សុពលភាពនៃសេវា និងការបង់ថ្លៃសេវាសោតទស្សន៍ទៅតាមប្រភេទសេវានីមួយៗ ដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងព័ត៌មាន។

**ប្រការ៦**: តម្លៃសេវាលើវិស័យព័ត៌មានដែលចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងរវាងក្រសួងព័ត៌មាន ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចកែប្រែបានដោយផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសំណើចាំបាច់របស់រដ្ឋបាលរាជធានី ខេត្តដោយយោងតាមស្ថានភាពជាក់ស្តែងនៃកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។

ការកែប្រែតម្លៃសេវានេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧**: រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំឲ្យមានកន្លែងទទួលពាក្យបណ្ដឹងតវ៉ានៅច្រកចេញចូលតែមួយ ដើម្បីទទួលពាក្យបណ្ដឹងតវ៉ាពីអ្នកស្នើសុំផ្ដល់សេវារដ្ឋបាលលើវិស័យព័ត៌មានដែលអាចកើតមានពីការអនុវត្តខុសស្ដង់ដាសេវា ឬការយកកម្រៃលើសការកំណត់ ឬការផ្ដល់សេវារដ្ឋបាលមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្ដឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយតាមគ្រប់មធ្យោបាយដូចជាៈ ការទទួលពាក្យបណ្ដឹងតវ៉ាដោយផ្ទាល់នៅកន្លែងច្រកចេញចូលតែមួយ ឬប្រអប់សំបុត្រនៅច្រកចេញចូលតែមួយ ឬតាមរយៈលេខទូរស័ព្ទ ឬសារអេឡិចត្រូនិក និង/ឬ អ្នកស្នើសុំអាចដាក់ពាក្យបណ្ដឹងទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីដោះស្រាយបណ្ដឹងរបស់ខ្លួន។

**ប្រការ៨** : រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំបង្កើតឲ្យមានយន្តការតាមដាន ត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីក្នុងការផ្ដល់សេវារដ្ឋបាលលើវិស័យព័ត៌មាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៩**: ការបែងចែកចំណូល ដែលប្រមូលបានពីការផ្ដល់សេវារដ្ឋបាលលើវិស័យព័ត៌មាន ការប្រមូលថ្លៃសេវាសោតទស្សន៍នៅរដ្ឋបាលរាជធានី ខេត្ត និងការបែងចែករង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភដល់បុគ្គលិក និងសម្រាប់ពង្រឹងយន្តការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត លើវិស័យព័ត៌មានដូចបានកំណត់នៅក្នុងប្រការ១ នៃប្រកាសនេះ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែមានការកំណត់ផ្សេងពីនេះ។

**ប្រការ១០**: រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្ដីពីស្ថានភាពនៃការអនុវត្តមុខងារជូនក្រសួងព័ត៌មានឲ្យបានទៀងទាត់ជារៀងរាល់ខែ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៥ នៃខែនីមួយៗ សម្រាប់របាយការណ៍ប្រចាំខែ និងឲ្យបានមុនថ្ងៃទី៣០ខែមករា សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ១១**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២**: នាយកខុទ្ទកាល័យក្រសួងព័ត៌មាន អគ្គនាយកនៃអគ្គនាយកដ្ឋានជំនាញ ប្រធាននាយកដ្ឋានជំនាញ ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត ប្រធានស្ថាប័ន និងប្រធានអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

<u>ចម្លងជូន</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានជំនាញចំណុះក្រសួងព័ត៌មាន
- អគ្គនាយកដ្ឋានពន្ធដារ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរព័ត៌មានរាជធានី ខេត្ត
- ដូចប្រការ១២ "ដើម្បីអនុវត្ត"
- ឯកសារ -កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

**ភ្ជាប់នឹងប្រកាសលេខ៣៥១៣.ម.ប្រក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងព័ត៌មាន**

**ស្តីពីការធ្វើប្រតិភូកម្មផ្ទេរមុខងារការផ្តល់សេវារដ្ឋបាលលើវិស័យព័ត៌មានជូនរដ្ឋបាលរាជធានី ខេត្ត**

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | ផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូ | | | |
| | -រយៈពេល១ឆ្នាំ | ១,២០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | -រយៈពេល៦ខែ | ៨០០,០០០ | ៧ថ្ងៃ | ៦ខែ |
| | -រយៈពេល៣ខែ | ៤០០,០០០ | ៧ថ្ងៃ | ៣ខែ |
| ២ | ផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ | | | |
| | -រយៈពេល១ឆ្នាំ | ៤០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | -រយៈពេល៦ខែ | ២០០,០០០ | ៧ថ្ងៃ | ៦ខែ |
| | -រយៈពេល៣ខែ | ១០០,០០០ | ៧ថ្ងៃ | ៣ខែ |
| ៣ | ផ្សព្វផ្សាយពាណិជ្ជកម្មតាមអាហ្វីស | ២០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៤ | ផ្សព្វផ្សាយពាណិជ្ជកម្មតាមប័ណ្ណប្រកាស | មិនគិតថ្លៃ | ៧ថ្ងៃ | ១ឆ្នាំ |
| ៥ | វាល់លិខិតអនុញ្ញាតសម្រាប់ឃោសនាមហាជន | មិនគិតថ្លៃ | ៧ថ្ងៃ | ១ឆ្នាំ |

ក្រសួងព័ត៌មាន

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៦ | **អាជីវកម្មគ្រឹះស្ថានបោះពុម្ពផ្សាយ** | | | |
| | -បន្តសុពលភាព | ៦០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៧ | **អាជីវកម្មរោងពុម្ព** | | | |
| | -បើក | ៨០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | -បន្តសុពលភាព | ៤០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៨ | **អាជីវកម្មស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប និងទូរទស្សន៍គ្រប់ប្រព័ន្ធផ្សាយផ្ទាល់ និងផ្សាយបន្តនៅតាមខេត្ត** [១] | | | |
| | -បន្តសុពលភាពអាជីវកម្មស្ថានីយវិទ្យុផ្សាយផ្ទាល់ | ៤០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | -បន្តសុពលភាពអាជីវកម្មស្ថានីយវិទ្យុផ្សាយបន្ត | ២០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | -បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយផ្ទាល់ | ៨០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | -បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយបន្ត | ៣០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | -បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ (ខ្សែកាប, MMDS, MUDS,DTV...) នៅរាជធានីភ្នំពេញ | ៨០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | -បន្តសុពលភាពអាជីវកម្មស្ថានីយទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ (ខ្សែកាប, MMDS, MUDS,DTV...) កំរិតស្រុក ឬឃុំ/សង្កាត់ | ៤០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៩ | អាជីវកម្មផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក (Online) | | | |
| | -បន្តសុពលភាព | ៨០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១០ | សេវាត្រួតពិនិត្យស្ថានីយវិទ្យុ ទូរទស្សន៍គ្រប់ប្រព័ន្ធ (២) | | | |
| | -ស្ថានីយវិទ្យុប្រចាំឆ្នាំ | ២០០,០០០ | | ១ឆ្នាំ |
| | -ស្ថានីយទូរទស្សន៍ ទូរទស្សន៍គ្រប់ប្រព័ន្ធប្រចាំឆ្នាំ | ៤០០,០០០ | | ១ឆ្នាំ |
| ១១ | អាជីវកម្មកាសែតផ្សាយជាភាសាជាតិ និងបរទេស | | | |
| | -បន្តសុពលភាព | ៥០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១២ | អាជីវកម្មកាសែតផ្សាយជាភាសាបរទេស និងភាសាជាតិ | | | |
| | -បន្តសុពលភាព | ១០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១៣ | អាជីវកម្មទស្សនាវដ្តី | | | |
| | -បន្តសុពលភាព | ៨០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១៤ | អាជីវកម្មព្រឹត្តបត្រភាសាជាតិ | | | |

ក្រសួងព័ត៌មាន

| | | | | |
|---|---|---|---|---|
| | -បន្តសុពលភាព | ៨០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៥ | អាជីវកម្មនាំចូលកាសែត និងទស្សនាវដ្តី | | | |
| | -បន្តសុពលភាព | ១០០,០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១៦ | សេវាសោតទស្សន៍ស្ថានីយវិទ្យុផ្សាយផ្ទាល់មានកម្លាំងផ្សាយ | | | |
| | -ចាប់ពី 100w ដល់ 2000w | ១,០០០,០០០ | | ១ឆ្នាំ |
| | -លើសពី 2000w ដល់ 5000w | ១,៥០០,០០០ | | ១ឆ្នាំ |
| | -លើសពី 5000w ដល់ 10000w | ៣,០០០,០០០ | | ១ឆ្នាំ |
| | -លើសពី 10000w | ៤,០០០,០០០ | | ១ឆ្នាំ |
| ១៧ | សេវាសោតទស្សន៍ស្ថានីយវិទ្យុផ្សាយបន្ត | ៥០០,០០០ | | ១ឆ្នាំ |
| ១៨ | សេវាសោតទស្សន៍ស្ថានីយទូរទស្សន៍ផ្សាយផ្ទាល់មានកម្លាំងផ្សាយ | | | |
| | -ចាបពី 100w ដល់ 2000w | ៣,០០០,០០០ | | ១ឆ្នាំ |
| | -លើសពី 2000w ដល់ 5000w | ៤,០០០,០០០ | | ១ឆ្នាំ |
| | -លើសពី 5000w ដល់ 10000w | ៥,០០០,០០០ | | ១ឆ្នាំ |

| | | | | |
|---|---|---|---|---|
| | -លើសពី 10000w | ១០,៥០០,០០០ | | ១ឆ្នាំ |
| ១៩ | សេវាសោតទស្សន៍ស្ថានីយទូរទស្សន៍ផ្សាយបន្ត | ១,០០០,០០០ | | ១ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២០ | សេវាសោតទស្សន៍ស្ថានីយទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗ (ទូរទស្សន៍ខ្សែកាប, MMDS, MUDS, DTV ... ) | | | |
| | -នៅរាជធានីភ្នំពេញ | ៧,០០០,០០០ | | ១ឆ្នាំ |
| | -ប្រកបអាជីវកម្មក្នុងកំរិត ស្រុក/ខណ្ឌ ឬឃុំ/សង្កាត់ | ១,០០០,០០០ | | ១ឆ្នាំ |
| ២១ | ផ្សាយ ( Spot ) ពាណិជ្ជកម្មតាមវិទ្យុជាតិកម្ពុជា នៅតាមខេត្ត (៣) | | | |
| | -តម្លៃទាបបំផុត (ក្នុង១នាទី) | ៤,០០០ | | |
| | -តម្លៃខ្ពស់បំផុត (ក្នុង១នាទី) | ៦,០០០ | | |
| ២២ | ផ្សាយដំណឹងផ្សេងៗ តាមវិទ្យុជាតិកម្ពុជា នៅតាមខេត្ត | | | |
| | -តម្លៃទាបបំផុត (១ទំព័រ A4) | ៣,០០០ | | |
| | -តម្លៃខ្ពស់បំផុត (១ទំព័រ A4) | ៥,០០០ | | |
| ២៣ | ផ្សាយ Spot ពាណិជ្ជកម្មតាមទូរទស្សន៍ជាតិកម្ពុជា នៅតាមខេត្ត | | | |
| | -តម្លៃទាបបំផុត (៣០វិនាទី) | ៣២,០០០ | | |
| | -តម្លៃខ្ពស់បំផុត (៣០វិនាទី) | ៦០,០០០ | | |

**<u>បញ្ជាក់:</u>**

(១)-ស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប និងទូរទស្សន៍គ្រប់ប្រព័ន្ធដែលមានទីតាំងផ្សាយផ្ទាល់នៅរាជធានី ខេត្ត ត្រូវបន្តសុពលភាព និងបង់ថ្លៃសេវាសោតទស្សន៍នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ស្ថិតនៅក្នុងដែនដីរបស់ខ្លួន លើកលែងតែស្ថានីយវិទ្យុ ទូរទស្សន៍ និងទូរទស្សន៍គ្រប់ប្រព័ន្ធដែលមានទីតាំងស្ថានីយផ្សាយផ្ទាល់នៅរាជធានីភ្នំពេញ ហើយមានស្ថានីយផ្សាយបន្តនៅតាមខេត្តនានា ត្រូវមកបន្តសុពលភាព និងបង់សេវាសោតទស្សន៍នៅច្រកចេញចូលតែមួយនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍នៃក្រសួងព័ត៌មាន។

-ស្ថានីយទូរទស្សន៍ខ្សែកាប និងទូរទស្សន៍គ្រប់ប្រព័ន្ធដែលមានលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្តាច់មុខនៅរាជធានី ខេត្ត ត្រូវមកបន្តសុពលភាពនៅច្រកចេញចូលតែមួយអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍នៃក្រសួងព័ត៌មាន។

-ស្ថានីយវិទ្យុ ទូរទស្សន៍ និងទូរទស្សន៍គ្រប់ប្រព័ន្ធផ្សាយផ្ទាល់នៅតាមខេត្តដែលមានស្ថានីយផ្សាយបន្តនៅតាមខេត្តនានា ត្រូវបន្តសុពលភាព និងបង់សេវាសោតទស្សន៍នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត ដែលមានស្ថានីយផ្សាយផ្ទាល់នៅទីនោះ។

(២) -សេវាត្រួតពិនិត្យប្រចាំឆ្នាំ (ក្នុងមួយឆ្នាំមួយលើក)ស្ថានីយវិទ្យុ ទូរទស្សន៍ និងទូរទស្សន៍គ្រប់ប្រព័ន្ធ ត្រូវធ្វើឡើងដោយមន្ទីរព័ត៌មានរាជធានី ខេត្ត ដែលមានទីតាំងនៅក្នុងដែនដីរបស់ខ្លួន។ លើកលែងតែការត្រួតពិនិត្យពិសេសបន្ទាន់តាមស្ថានីយវិទ្យុ ទូរទស្សន៍ និងទូរទស្សន៍គ្រប់ប្រព័ន្ធ ត្រូវធ្វើឡើងដោយមន្ត្រីជំនាញរបស់ក្រសួងព័ត៌មាន។

(៣)-ផ្សាយស្ប៉តពាណិជ្ជកម្ម និងដំណឹងផ្សេងៗនៅស្ថានីយវិទ្យុជាតិ និងទូរទស្សន៍ជាតិកម្ពុជា ដែលមានទីតាំងនៅរាជធានីភ្នំពេញ ត្រូវបង់ថ្លៃសេវាផ្សាយពាណិជ្ជកម្មនៅច្រកចេញចូលតែមួយនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍នៃក្រសួងព័ត៌មាន។

-ផ្សាយស្ប៉តពាណិជ្ជកម្ម និងដំណឹងផ្សេងៗនៅស្ថានីយវិទ្យុជាតិ និងទូរទស្សន៍ជាតិកម្ពុជា ដែលមានទីតាំងនៅតាមខេត្តនានា ត្រូវបង់ថ្លៃសេវាផ្សាយពាណិជ្ជកម្មនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តសាមី។

ក្រសួងព័ត៌មាន